# ក

## មាតិកា

## I.ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ១៣-៥-២០០៣ | -ព្រះរាជក្រឹត្យ នស/រកត/០៥០៣/១៧៤ ស្តីពីការផ្លាស់ឯកឧត្តម **ស៊ុន សួន** បច្ចុប្បន្ន អគ្គរាជទូត និងជាតំណាងអចិន្ត្រៃយ៍រង នៃស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជាប្រចាំ អង្គការសហប្រជាជាតិ ឱ្យមកបំរើការងារនៅក្នុងប្រទេសវិញ ដោយចប់អាណត្តិបេសកកម្ម | ២០០៤ |
| ១៣-៥-២០០៣ | -ព្រះរាជក្រឹត្យ នស/រកត/០៥០៣/១៧៥ ស្តីពីការផ្លាស់ឯកឧត្តម **ស៊ា កុសល** បច្ចុប្បន្ន អគ្គាធិការ នៃអគ្គាធិការដ្ឋានក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឱ្យទៅបំពេញការងារ នៅឯបរទេស | ២០០៥ |
| ២១-៥-២០០៣ | -ព្រះរាជក្រឹត្យ នស/រកត/០៥០៣/១៧៦ ស្តីពីការប្រោសព្រះរាជទានគ្រឿង ឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** | ២០០៦ |
| ២៧-៥-២០០៣ | -ព្រះរាជក្រឹត្យ នស/រកត/០៥០៣/១៨៤ ស្តីពីការតែងតាំងឯកឧត្តម **ប្រាក់ ចាន់ធឿន** ជាអគ្គាធិការ នៃអគ្គាធិការដ្ឋានក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា | ២០០៧ |


## II.រាជរដ្ឋាភិបាល

### អនុក្រឹត្យ


| | | |
|---|---|---|
| ៣០-៥-២០០៣ | -អនុក្រឹត្យលេខ ៤៩៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២០០៨ |
| ០៣-៥-២០០៣ | -អនុក្រឹត្យលេខ ៤៩៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ២០១០ |
| ០៣-៥-២០០៣ | -អនុក្រឹត្យលេខ ៤៩៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២០១១ |
| ០៣-៥-២០០៣ | -អនុក្រឹត្យលេខ ៤៩៩ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី | ២០១២ |
| ០៣-៥-២០០៣ | -អនុក្រឹត្យលេខ ៥០០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២០១៣ |
| ០៣-៥-២០០៣ | -អនុក្រឹត្យលេខ ៥០១ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ២០១៤ |
| ០៣-៥-២០០៣ | -អនុក្រឹត្យលេខ ៥០២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ២០១៧ |
| ០៤-៥-២០០៣ | -អនុក្រឹត្យលេខ ៥០៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២០១៨ |
| ០៤-៥-២០០៣ | -អនុក្រឹត្យលេខ ៥០៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២០១៩ |
| ០៤-៥-២០០៣ | -អនុក្រឹត្យលេខ ៥០៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២០២០ |
| ០៤-៥-២០០៣ | -អនុក្រឹត្យលេខ ៥០៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២០២១ |
| ០៤-៥-២០០៣ | -អនុក្រឹត្យលេខ ៥០៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២០២២ |

# ខ


០៥-៥-២០០៣ -អនុក្រឹត្យលេខ ៥០៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២០២៣

០៥-៥-២០០៣ -អនុក្រឹត្យលេខ ៥០៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២០២៥

០៥-៥-២០០៣ -អនុក្រឹត្យលេខ ៥១០ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា ២០២៦

០៦-៥-២០០៣ -អនុក្រឹត្យលេខ ៥១១ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២០២៧

០៦-៥-២០០៣ -អនុក្រឹត្យលេខ ៥១២ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ២០២៨

០៦-៥-២០០៣ -អនុក្រឹត្យលេខ ៥១៣ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិជាកិច្ចបច្ឆាមរណៈ ២០២៩

## III-ការងារបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៧-៥-២០០៣ -ប្រកាសលេខ ១៤០ MOC/M 2003 ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានស្ថិតិ និងពតិមាន ២០៣១

២៧-៥-២០០៣ -ប្រកាសលេខ ១៤១ MOC/M 2003 ស្តីពីការបង្កើតបន្ថែមការិយាល័យមួយចំណុះនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ ២០៣៤

២៧-៥-២០០៣ -ប្រកាសលេខ ១៤២ MOC/M 2003 ស្តីពីការបង្កើតបន្ថែមការិយាល័យពីរចំណុះនាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ ២០៣៦

### ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

២៦-៥-២០០៣ -ប្រកាសលេខ ១៥៨/០៣ ព.ម ប្រក ស្តីពីការអនុញ្ញាតឱ្យកាសែត"**គតិយលោក**" បោះពុម្ពចែកផ្សាយដោយមានលោក **ណុប ទុទ្ធី** ជាចាងហ្វាងការផ្សាយ ២០៣៨

៣០-៥-២០០៣ -ប្រកាសលេខ ១៦៣/០៣ ព.ម ស្តីពីការអនុញ្ញាតឱ្យកាសែត"**កោះសុវណ្ណភូមិ**" បោះពុម្ពចែកផ្សាយដោយមានលោក **ឈឹន ឆាយ** ជាចាងហ្វាងការផ្សាយ ២០៣៩

៣០-៥-២០០៣ -ប្រកាសលេខ ១៦៤/០៣ ព.ម ស្តីពីការអនុញ្ញាតឱ្យព្រឹត្តិប័ត្រប្រចាំសប្តាហ៍ "**កញ្ចក់សង្គម**" និង"**The Mirror**" បន្តអាជ្ញាប័ណ្ណបោះពុម្ពចែកផ្សាយដោយមានលោក **Nobert Klein** ជាចាងហ្វាងការផ្សាយ ២០៤០

៣០-៥-២០០៣ -ប្រកាសលេខ ១៦៥/០៣ ព.ម ប្រក ស្តីពីការអនុញ្ញាតឱ្យកាសែត"**ព្រះខ័ន**" បោះពុម្ពចែកផ្សាយដោយមានលោកស្រី **អេង សុខខឺង** ជាចាងហ្វាងការផ្សាយ ២០៤១

៣០-៥-២០០៣ -ប្រកាសលេខ ១៦៦/០៣ ព.ម ប្រក ស្តីពីការអនុញ្ញាតឱ្យកាសែត"**ចក្រភព**" បោះពុម្ពចែកផ្សាយដោយមានលោកស្រី **សុខ ខុម** ជាចាងហ្វាងការផ្សាយ ២០៤២

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៣/១៧៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានផ្លាស់ឯកឧត្តម **ស៊ុន សួន** បច្ចុប្បន្ន អគ្គរាជទូត និងជាតំណាងអចិន្ត្រៃយ៍រង នៃស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជា ប្រចាំអង្គការសហប្រជាជាតិ អោយមកបំរើការងារនៅក្នុងប្រទេសវិញ ដោយចប់អាណត្តិបេសកកម្ម ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ ឧសភា ឆ្នាំ ២០០៣*

*ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាត្រាស់បង្គាប់*

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

៣៧ល.០៣.០៥.១៨៥

លេខ:១៥៣ច ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ០៦ ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាខី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៣/១៧៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានផ្លាស់ឯកឧត្តម **ស៊ា គុសល** បច្ចុប្បន្នអគ្គាធិការ នៃអគ្គាធិការដ្ឋានក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អោយទៅបំពេញការងារនៅឯបរទេស ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៣*

*ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់*

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

៣រស.០៣.០៥.១៨៦

លេខ: ១៤៦ ច ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០០៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ណារី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៣/១៧៦

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា )

ត្រាស់ព្រះរាជឱង្ការ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :
១-ឯកឧត្តម ទេព សីវុឌ្ឍ
២-ឯកឧត្តម ថោង ខុន

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :
- ឯកឧត្តម នុត និនជឿន

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :
១-ឯកឧត្តម សំ ព្រហ្មនា
២-ឯកឧត្តម រស់ រ៉េន
៣-ឯកឧត្តម សូ ម៉ារ៉ា

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :
១-ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ជីវណ្ណាឫទ្ធិ
២-លោកជំទាវ ឱម សោមស៊ីន
៣-ឯកឧត្តម ជ័យ សម្បូរណ៍
៤-ឯកឧត្តម គោស៊ុំ សារឿត

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែឧសភា ឆ្នាំ ២០០៣

ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

លេខ: ១៥៤ ច ល

ទាល. ០៣.០៥.២៨៧

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០០៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៣/១៨៤

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

* * *

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : តែងតាំងឯកឧត្តម **ឃ្លាក់ ចាន់ធឿន** ជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ។

**មាត្រា ២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៣*

**ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

លេខ: ១៥៧ ច ល

**ជា ស៊ីម**

ចារ.០៣.០៥.១៩៥ ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាវី តាន់**

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៤៩ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

## ស ម្រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេនព្រះសង្ឃ ចំនួន ០២អង្គ និង សប្បុរសជន ចំនួន ១១រូប ដែលបានបរិច្ចាគ កំលាំងកាយចិត្ត និង ធនធានជួយកសាង សមិទ្ធផលផ្សេងៗ នៅឃុំពពេល ស្រុកពញាក្រែក ខេត្តកំពង់ចាម និង នៅវត្ត នទីសោតនារាម " ស្ទឹងស្លូត " ឃុំអ្នកលឿង ស្រុកពាមរក៍ ខេត្តព្រៃវែង ដូចមាន រាយព្រះនាម និង នាម ខាងក្រោម :-

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណ | **ញូង** | **នុត** | ចៅអធិការវត្តបទុមព្រឹក្ស ឃុំពពេល ស្រុកពញាក្រែក ខេត្តកំពង់ចាម | |
| ២-ព្រះតេជគុណ | **សាន** | **រស់** | ចៅអធិការវត្ត នទីសោតនារាម "ស្ទឹងស្លូត" ឃុំអ្នកលឿង ស្រុកពាមរក៍ ខេត្តព្រៃវែង | |
| ៣-លោកជំទាវ | **នន** | **ម៉ែន** | ភរិយា ឯកឧត្តម **គង់ ណែម** | |
| ៤-ឧកញ៉ា | **គ្រីតនី** | **ម៉ែន** | បានចំណាយ ថវិកា | ១០.០០០ ដុល្លារអាមេរិក |
| ៥-លោក | **ព្រាប** | **គឹមសាន្ត** | បានចំណាយ ថវិកា | ១០.០០០ ដុល្លារអាមេរិក |
| ៦-លោក | **ហាក់** | **ឡេង** | បានចំណាយ ថវិកា | ១០.០០០ ដុល្លារអាមេរិក |
| ៧-លោក | **ចេន** | **ឌីជាង** | បានចំណាយ ថវិកា | ១០.០០០ ដុល្លារអាមេរិក |
| ៨-លោក | **ហាវ** | **ស្រ៊ាង** | បានចំណាយ ថវិកា | ១០.០០០ ដុល្លារអាមេរិក |
| ៩-លោក | **ចាន់** | **តា** | បានចំណាយ ថវិកា | ១០.០០០ ដុល្លារអាមេរិក |
| ១០-លោក | **អ៊ុំ** | **សុឃឹម** | បានចំណាយ ថវិកា | ១០.០០០ ដុល្លារអាមេរិក |

| | | | | |
|---|---|---|---|---|
| ១១-លោក | **ភូ** | **ជី** | បានចំណាយ ថវិកា | ១០.០០០ ដុល្លារអាមេរិក |
| ១២-លោក | **សេង** | **ឈួន** | បានចំណាយ ថវិកា | ១០.០០០ ដុល្លារអាមេរិក |
| ១៣-លោក | **ឈាំង** | **ហ៊ីម** | បានចំណាយ ថវិកា | ១០.០០០ ដុល្លារអាមេរិក |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អនុប្រធានទី១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

JSK3.1.doc

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៩៧ អនក្រ-តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

*******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## សំរេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **គីម សន្តិភាព** ជាអធិការ នៃអគ្គាធិការដ្ឋានកិច្ចការតុលាការ ក្រសួងយុត្តិធម៌ ទទួលបន្ទុកការងាររដ្ឋបាល ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៩៨ អនក្រ-ធក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

## សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន កូរ៉េ ចំនួន០៣រូប ដែលបានដឹកនាំការងារ និងឧបត្ថម្ភនូវសម្ភារៈសម្រាប់ហ្វឹកហ្វឺន ម៉ាស៊ីន Comprssor និង បំពង់អុកស៊ីសែន ជូនកងពលតូចទ័ពពិសេស ឆ័ត្រយោង លេខ ៩១១ ដូចមានរាយនាមខាងក្រោម :-

១-លោក **JUN BYUNG MAN** អនុប្រធានសមាគមកូរ៉េ នៅកម្ពុជា ឧបត្ថម្ភសម្ភារៈ មានតម្លៃស្មើនឹង ៤០.000 USD

២-លោក **KIM JONG PAL** ប្រធានក្រុមហ៊ុនដឹកជញ្ជូន កូរ៉េ ឧបត្ថម្ភសម្ភារៈ មានតម្លៃស្មើនឹង ២៥.000 USD

៣-លោក **PARK SANG TAE** អនុប្រធានក្រុមហ៊ុនដឹកជញ្ជូន កូរ៉េ ឧបត្ថម្ភសម្ភារៈ មានតម្លៃស្មើនឹង ១៥.000 USD

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ៦ ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច ✓
-ឯកសារ-កាលប្បវត្តិ

105

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៤៩៦ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

### សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនគ្រូបង្វឹក ជនជាតិកូរ៉េ ចំនួន០៤រូប ដែលមានស្នាដៃល្អ ក្នុងការជួយបង្វឹកជំនាញ Scuba និង HAPKIDO ដល់នាយទាហាន ពលទាហាន នៃកងពលតូច ទ័ពពិសេសឆ័ត្រយោង លេខ ៩១១ ដូចមានរាយនាមខាងក្រោម :-

| | | |
|---|---|---|
| ១-លោក | JUN KYUNG SHIK | ប្រធានក្រុមគ្រូបង្វឹក Scuba |
| ២-លោក | BAE DUCK JIN | គ្រូបង្វឹក Scuba |
| ៣-លោក | PARK DONG HOON | គ្រូបង្វឹក Scuba |
| ៤-លោក | KANG SUNG MIN | គ្រូបង្វឹក Scuba |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធពល ខេមរភូមិន្ទ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:.៥០០..អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

## សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនឯកឧត្តម Gotaro OGAWA ឯកអគ្គរាជទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានផ្តល់អំណោយ ជាទឹកប្រាក់ ចំនួន ៣២.៦៤៨ ដុល្លារអាមេរិក សំរាប់សាងសង់ អគារសិក្សា ០១ខ្នង មាន ០៦បន្ទប់ បំពាក់ដោយសម្ភារៈសិក្សាគ្រប់គ្រាន់ រួមទាំង បង្គន់អនាម័យ និង អណ្តូងទឹក នៅសាលាបឋមសិក្សាកំពង់ពោធិ៍ ឃុំកំពង់ពោធិ៍ ស្រុកក្រគរ ខេត្ត ពោធិសាត់ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាល ខេត្តពោធិសាត់ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥០១ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

## សំរេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន ៦១រូប នៃក្រសួងធម្មការ និង សាសនា ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចលើការងារធម្មការ និង សាសនា ឆ្នាំ ២០០២ ដូចមានរាយនាមខាងក្រោមនេះ :-

**ក_មេដាយមាសការងារ ជាកិច្ចបច្ឆាមរណៈ :**

-លោក **អ៊ឹម ឈុនលី** អតីតប្រធានមន្ទីរធម្មការ និង សាសនា ខេត្តកំពង់ឆ្នាំង

**ខ_មេដាយប្រាក់ការងារ :**

១-លោក **ឌី សុម៉ាលី** ប្រធានមន្ទីរធម្មការ និង សាសនា ខេត្តបាត់ដំបង

២-លោក **ចៅ កាស៊ីណូត៍** ប្រធានមន្ទីរធម្មការ និង សាសនា ខេត្តបន្ទាយមានជ័យ

៣-លោក **ខន្ស សារមេត** ប្រធានមន្ទីរធម្មការ និង សាសនា ខេត្តកំពត

៤-លោក **នេត ធន់** ប្រធានមន្ទីរធម្មការ និង សាសនា ខេត្តស្វាយរៀង

៥-លោក **ញាណ សារ៉ា** ប្រធានមន្ទីរធម្មការ និង សាសនា ខេត្តក្រចេះ

៦-លោកស្រី **យឹម ស៊ុនអោខ** ប្រធានមន្ទីរធម្មការ និង សាសនា ខេត្តកណ្តាល

៧-លោកស្រី **នឹម អ៊ុន** ប្រធានមន្ទីរធម្មការ និង សាសនា ខេត្តកំពង់ស្ពឺ

៨-លោក **ស សែត** ប្រធានមន្ទីរធម្មការ និង សាសនា ខេត្តព្រៃវែង

៩-លោក **ជួន សារឿន** ប្រធានមន្ទីរធម្មការ និង សាសនា ខេត្តកោះកុង

១០-លោក **ឌុយ ហួយ** ប្រធានមន្ទីរធម្មការ និង សាសនា ខេត្តសៀមរាប

40

១១-លោក ញ៉ុំ ស៊ូ ប្រធានមន្ទីរធម្មការ និង សាសនា ខេត្តព្រះវិហារ
១២-លោក ម៉ៅ ផុន ប្រធានមន្ទីរធម្មការ និង សាសនា ក្រុងព្រះសីហនុ
១៣-លោក គីម សួរ ប្រធានមន្ទីរធម្មការ និង សាសនា ខេត្តកំពង់ធំ
១៤-លោក សារ គុយ ប្រធានមន្ទីរធម្មការ និង សាសនា ខេត្តឧត្តរមានជ័យ
១៥-លោក ញ៉ាង ប៊ុនថន ប្រធានមន្ទីរធម្មការ និង សាសនា ខេត្តរតនគិរី
១៦-លោក ស៊ី សួន ប្រធានមន្ទីរធម្មការ និង សាសនា ខេត្តស្ទឹងត្រែង
១៧-លោក ឃឹម ប៊ិន ប្រធានមន្ទីរធម្មការ និង សាសនា ខេត្តមណ្ឌលគិរី
១៨-លោក ទឹម ញៀម ប្រធានមន្ទីរធម្មការ និង សាសនា ខេត្តពោធិសាត់
១៩-លោក សំ អ៊ុចពៅ ប្រធានមន្ទីរធម្មការ និង សាសនា ក្រុងប៉ៃលិន
២០-លោក ខៀត ចំនួបូរ ប្រធានមន្ទីរធម្មការ និង សាសនា រាជធានីភ្នំពេញ
២១-លោក ពុធ ខូច ប្រធានមន្ទីរធម្មការ និង សាសនា ខេត្តតាកែវ
២២-លោកស្រី សំ សាធី ប្រធានមន្ទីរធម្មការ និង សាសនា ខេត្តកំពង់ឆ្នាំង

**គ.មេដាយសំរិទ្ធការងារ :**

១-លោកស្រី ហ៊ុន ទូចឡេង ប្រធានការិយាល័យ ធម្មការ
២-លោក សោម យេន ប្រធានការិយាល័យ អធិការកិច្ច
៣-លោក នូ ចំនួដារ៉ា អនុប្រធានមន្ទីរធម្មការ និង សាសនា ខេត្តក្រចេះ
៤-លោក ដៃ សុខន អនុប្រធានមន្ទីរធម្មការ និង សាសនា ខេត្តកណ្តាល
៥-លោក សំ សារឿន អនុប្រធានមន្ទីរធម្មការ និង សាសនា ក្រុងប៉ៃលិន
៦-លោក វ៉ាយ ពុំ អនុប្រធានមន្ទីរធម្មការ និង សាសនា ក្រុងប៉ៃលិន
៧-លោក គីម ភាង អនុប្រធានមន្ទីរធម្មការ និង សាសនា ខេត្តបាត់ដំបង
៨-លោក គង់ សាន អនុប្រធានមន្ទីរធម្មការ និង សាសនា ខេត្តបាត់ដំបង
៩-លោក យក់ សាន់ អនុប្រធានមន្ទីរធម្មការ និង សាសនា ខេត្តកំពង់ធំ
១០-លោក ឈាម សារុន អនុប្រធានមន្ទីរធម្មការ និង សាសនា ខេត្តកំពង់ធំ
១១-លោក ឡឹក សោភ័ណ អនុប្រធានមន្ទីរធម្មការ និង សាសនា ក្រុងកែប
១២-លោក ផន ជាទី អនុប្រធានមន្ទីរធម្មការ និង សាសនា រាជធានីភ្នំពេញ
១៣-លោក មាស ញ៉ិល អនុប្រធានមន្ទីរធម្មការ និង សាសនា រាជធានីភ្នំពេញ
១៤-លោក ស៊ីល សុខសារ៉ន អនុប្រធានមន្ទីរធម្មការ និង សាសនា ខេត្តតាកែវ
១៥-លោក កែម ហ៊ុច អនុប្រធានមន្ទីរធម្មការ និង សាសនា ខេត្តតាកែវ
១៦-លោក ម៉េង ប៉ន អនុប្រធានមន្ទីរធម្មការ និង សាសនា ខេត្តកំពត
១៧-លោក ម៉ន ដេង អនុប្រធានមន្ទីរធម្មការ និង សាសនា ខេត្តកំពត
១៨-លោក នួច ស្មី អនុប្រធានមន្ទីរធម្មការ និង សាសនា ខេត្តមណ្ឌលគិរី
១៩-លោក ឯក នួច អនុប្រធានមន្ទីរធម្មការ និង សាសនា ខេត្តកោះកុង
២០-លោក សុខ ឡាង អនុប្រធានមន្ទីរធម្មការ និង សាសនា ក្រុងព្រះសីហនុ
២១-លោក អ៊ូ សារូ អនុប្រធានមន្ទីរធម្មការ និង សាសនា ខេត្តពោធិសាត់

២២-លោក កែវ សាវុធ អនុប្រធានមន្ទីរធម្មការ និង សាសនា ខេត្តពោធិសាត់
២៣-លោក ហ៊ិន សាមី អនុប្រធានមន្ទីរធម្មការ និង សាសនា ខេត្តពោធិសាត់
២៤-លោក គុប ហឿន អនុប្រធានមន្ទីរធម្មការ និង សាសនា ខេត្តព្រៃវែង
២៥-លោក មុំ ចំន្ទតារា អនុប្រធានមន្ទីរធម្មការ និង សាសនា ខេត្តព្រៃវែង
២៦-លោក ដាំ អ៊ុយ អនុប្រធានមន្ទីរធម្មការ និង សាសនា ខេត្តស្ទឹងត្រែង
២៧-លោក ឆិត សិត់ អនុប្រធានមន្ទីរធម្មការ និង សាសនា ខេត្តឧត្តរមានជ័យ
២៨-លោក លី ស្រាច អនុប្រធានមន្ទីរធម្មការ និង សាសនា ខេត្តឧត្តរមានជ័យ
២៩-លោក ម៉ុត សារុន អនុប្រធានមន្ទីរធម្មការ និង សាសនា ខេត្តបន្ទាយមានជ័យ
៣០-លោក ឯក សុភី អនុប្រធានមន្ទីរធម្មការ និង សាសនា ខេត្តបន្ទាយមានជ័យ
៣១-លោក សូ ខាត់ អនុប្រធានមន្ទីរធម្មការ និង សាសនា ខេត្តកំពង់ស្ពឺ
៣២-លោក ឆេត ណារ៉ា អនុប្រធានមន្ទីរធម្មការ និង សាសនា ខេត្តរតនគិរី
៣៣-លោក ម៉ាន់ សុឌ្ឍី អនុប្រធានមន្ទីរធម្មការ និង សាសនា ខេត្តកំពង់ឆ្នាំង
៣៤-លោក នៅ គឹម អនុប្រធានការិយាល័យ ពុទ្ធិកមធ្យមសិក្សា
៣៥-លោក ឆយ អូន អនុប្រធានការិយាល័យ បុគ្គលិក
៣៦-លោក ស៊ឹម សារិទ្ធ អនុប្រធានការិយាល័យ ពុទ្ធិកមហាវិទ្យាល័យ
៣៧-លោក ឃួរ ជុច មន្ត្រីការិយាល័យសំភារៈបរិក្ខារ
៣៨-លោកស្រី ភាន់ ឡាយ មន្ត្រីការិយាល័យ បណ្ណាល័យ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៣
**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥០២ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ /នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និង ដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន
- យោងតាមសំណើរបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន

## សំរេច

**មាត្រា ១** : ត្រូវបានតែងតាំងលោក **សុខុម ទីរផល** ជាប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក នៃអគ្គនាយកដ្ឋានដឹកជញ្ជូន ក្រសួងសាធារណការ និង ដឹកជញ្ជូន ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ_កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ...៥០.អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០២គ្រឿង ជូនសប្បុរសជន ០២រូប ដែលបានរួមគ្គាបរិច្ចាគធនធាន ជួយកសាងស្ពានមួយកន្លែង នៅវត្តកោះកែវអំណែត ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល ចំណាយអស់ទឹកប្រាក់ ចំនួន ៤៣.៨២០ USD ដូចមាននាមខាងក្រោម :-

១-លោក **គួង ច្រឹនខន**

២-លោកស្រី **ស៊ុយ ឌឹម**

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

91

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ...៥០៤...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០២គ្រឿង ជូនសប្បុរសជន ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលផ្សេងៗ ក្នុងវិស័យព្រះពុទ្ធសាសនា នៅខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :-

| | | | | |
|---|---|---|---|---|
| ១-លោក | **សៀ** | **សុវណ្ណឫទ្ធិ** | បានជួយកសាងព្រះវិហារ វត្តនិគ្រោធារាម ឃុំប៉ុស២<br>ស្រុកក្រូចឆ្មារ | អស់ទឹកប្រាក់ ១០.៣៥០ USD |
| ២-លោក | **តៅ** | **ទិច្ឆិកា** | បានជួយកសាងប្រាសាទព្រះនគរ ក្នុងវត្តព្រះនគរ<br>ស្រុកកំពង់ សៀម | អស់ទឹកប្រាក់ ១៥.៣៥៥ USD |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៥០.៥...អនក្រ-តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ហ៊ឹម សារ៉ាន់** មន្ត្រីយោធា នៅក្រុងភ្នំពេញ ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាង ព្រះវិហារ កុដិ និង ព្រះពុទ្ធរូប នៅវត្តសុវណ្ណតេជោ ឃុំសារិកាកែវ ស្រុកល្វាឯម ខេត្តកណ្តាល ចំណាយអស់ទឹកប្រាក់ ចំនួន ៣០.០០០ ដុល្លារអាមេរិក ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥០៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជន ចំនួន ០៦រូប ដែលបាន បរិច្ចាគបច្ច័យ និង ធនធាន ជួយកសាងព្រះវិហារ និង កុដិ នៅវត្តភ្នំតូច ឃុំរលាំងចក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដូចមានរាយ ព្រះនាម និង នាមខាងក្រោម :-

**ក.មេដាយមាសស្ថាបនាជាតិ :**

| | | | | | |
|---|---|---|---|---|---|
| ១-ព្រះតេជគុណ | **ហ៊ិន យោង** | ចៅអធិការវត្តភ្នំតូច | បច្ច័យ | ១៥.៣០០ | ដុល្លារ |
| ២-លោកស្រី | **សុខ ឈន់លី** | នៅសហរដ្ឋអាមេរិក | ថវិកា | ១២.០០០ | ដុល្លារ |
| ៣-លោក | **គឹម ឌុល** | នៅក្រុងភ្នំពេញ | ថវិកា | ១០.១៥០ | ដុល្លារ |

**ខ.មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | | | |
|---|---|---|---|---|---|
| -លោក | **ប្រាជ្ញ ច័ន** និង ភរិយា | នៅសហរដ្ឋអាមេរិក | ថវិកា | ៦.០០០ | ដុល្លារ |

**គ.មេដាយសំរឹទ្ធស្ថាបនាជាតិ :**

| | | | | | |
|---|---|---|---|---|---|
| ១-លោក | **នួច នៃ** | នៅភូមិរលាំងគ្រើល | ថវិកា | ៣.៤៤០ | ដុល្លារ |
| ២-លោក | **ចេង ខេង** | នៅក្រុងភ្នំពេញ | ថវិកា | ៣.៤៤០ | ដុល្លារ |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តព្រៃវែង

## ស ំ រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០២ រូប ដែលបានបរិច្ចាគធនធាន ផ្ទាល់ខ្លួន ជួយកសាងសមិទ្ធផលផ្សេងៗ ក្នុងវិស័យអប់រំ សុខាភិបាល គមនាគមន៍ និង ព្រះពុទ្ធសាសនា ក្នុង ស្រុកកំពង់លាវ ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោម :-

| | | | |
|---|---|---|---|
| ១-លោកជំទាវ | **ឡុង សាខន ~ ស៊ិន សុខ** | បរិច្ចាគ ថវិកា | ២០.០០០ ដុល្លារ |
| ២-លោក | **និត សុន** | បរិច្ចាគ ថវិកា | ១០.៥០០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៥០៧...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកំពង់ធំ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជនចំនួន ១៣ រូប ដែលបានជួយឧបត្ថម្ភថវិកាផ្ទាល់ខ្លួន និងខិតខំធ្វើសកម្មភាពក្នុងការកសាងសមិទ្ធផលនានា ស្ថិតនៅក្នុងស្រុកបារាយណ៍ ខេត្តកំពង់ធំ ដូចមានរាយព្រះនាម និង នាមខាងក្រោម ÷

**ក-មេដាយមាសស្ថាបនាជាតិ :**

១-ព្រះតេជគុណ **សុត ចំនួនវណ្ណា** ព្រះចៅអធិការវត្តស្វាយ

២-ឯកឧត្តម **ថោង ខុន** រដ្ឋលេខាធិការក្រសួងទេសចរណ៍ ថវិកា ៩៩.៦៥៨ USD

៣-ឯកឧត្តម **ចៅ ទ្រី** អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ធំ ថវិកា ៤៨.៦៧០ USD

៤-ឯកឧត្តម **ខៀវ ហ៊ល** អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ធំ ថវិកា ៤២.៣២៥USD

៥-ឯកឧត្តម **ញៀម ថ្លាវី** ទីប្រឹក្សា ឯកឧត្តម **ខួន ញឹល** អនុប្រធានទី២ រដ្ឋសភា ថវិកា ៤៥.៧៥០ USD

៦-លោក **ខៀវ សុខុម** នាយរងខុទ្ទកាល័យសាលាក្រុងភ្នំពេញ ថវិកា ១១.០០០ USD

៧-លោក **ជាតិ ស៊ីថុល្លា** ប្រធានមន្ទីរធនធានទឹកនិងឧតុនិយមខេត្ត ថវិកា ១៣.៨៥០ USD

៨-លោក **ម៉ៅ ឡាំង** ប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្ត ថវិកា ២៥.៣០៥ USD

៩-លោក **ជា ចៅវ៉ាង** អធិការនៃអគ្គាធិការដ្ឋានក្រសួងអភិវឌ្ឍន៍ជនបទ ថវិកា៣២.០០០ USD

១០-កញ្ញា **អ៊ុំ ស្តុំទីង** ប្រធានអង្គការ មេត្តឌីស -បំរើកម្ពុជា ប្រចាំស្រុកបារាយណ៍ ថវិកា ២៧៩.៦៧៧ USD

4

**ខ.មេដាយប្រាក់ស្ថាបនាជាតិ :**

-លោក **សុក ឈាង** អភិបាលស្រុកបារាយណ៍ ថវិកា ៥.៣២០ USD

**គ.មេដាយសំរឹទ្ធស្ថាបនាជាតិ :**

១-លោក **ម៉ុន ឈួន** អភិបាលរងស្រុកបារាយណ៍ ថវិកា ៤.២៧០ USD

២-លោក **ហាក់ ម៉ូងសេង** អភិបាលរងស្រុកបារាយណ៍ ថវិកា ៤.៣២០ USD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ ៕

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៥០៩.....អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៣ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងបណ្តុះបណ្តាល ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

## សំរេច

**មាត្រា ១ :** តែងតាំងលោក **ខេត ប៊ុន្ថា** ជាប្រធាននាយកដ្ឋានផែនការ_ហិរញ្ញវត្ថុ នៃអគ្គនាយកដ្ឋានរដ្ឋបាល របស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ ២០០៣*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*

*ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ....៥១០....អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## ស ំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសុវត្ថារា** តាមលំដាប់ថ្នាក់ជូនមន្ត្រីថ្នាក់ដឹកនាំ ចំនួន ០៣ រូប ដែលមានស្នាដៃក្នុងការអនុវត្តន៍ការងារអភិវឌ្ឍន៍ជនបទ ជូនជាតិ និង ប្រជាជន ទទួលបានលទ្ធផលគួរជាទីមោទនៈ ដូចមានរាយនាមខាងក្រោម ÷

**ក-មេដាយសុវត្ថារា** ថ្នាក់ **សេនា :**

១-ឯកឧត្តម **លី ប្រួស** អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ

២-ឯកឧត្តម **ទ្រី មេង** អគ្គនាយកបច្ចេកទេស

**ខ-មេដាយសុវត្ថារា** ថ្នាក់ **អស្សឫទ្ធិ :**

-ឯកឧត្តម **ស្វាយ រ៉េត** អគ្គាធិការ

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៥១១ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តកំពង់ចាម

## ស ំ រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនឧកញ៉ា **ហែម ថេង** ដែលបានបរិច្ចាគនូវ កំលាំងកាយ ចិត្ត និង ធនធានផ្ទាល់ខ្លួន ចូលរួមចំណែកកសាងសមិទ្ធផលផ្សេងៗ ក្នុងវិស័យព្រះពុទ្ធ សាសនា អប់រំ និង សង្គមកិច្ច ចំណាយអស់ទឹកប្រាក់ សរុបចំនួន ២៩២.០៣៧ ដុល្លារអាមេរិក ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុ ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៦៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សរិទ្ធិ** ជូនអ្នកជំនាញការជប៉ុន ចំនួន ០២ រូប ដែលបានសហការជួយដល់ការងាររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា / គណៈកម្មាធិការនីតិសម្បទា និង អភិវឌ្ឍន៍ (កអក/គជនា) សំរេចបានលទ្ធផលល្អប្រសើរ ដូចមាននាមខាងក្រោម :-

១-លោកស្រី **Michiko UMEZAKI**

២-លោកស្រី **Itsu ADACHI**

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

122

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥១៣.អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរសក្តិជាកិច្ចបច្ឆាមរណ:
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

**<u>ស ំ ម្រ េ ច</u>**

**មាត្រា១** : ត្រូវបានតម្លើងឋានន្តរសក្តិ **ថ្នាក់ឧត្តមសេនីយ៍ឯក** ជាកិច្ចបច្ឆាមរណ:ជូនសព

| | | | | |
|---|---|---|---|---|
| ១-វរសេនីយ៍ទោ | សារ៉ាយ | សម្បត្តិ | អត្តលេខ ០០១១០៦ | នាយរងការិយាល័យផែនការ ទីចាត់ការហ្វឹកហ្វឺន អគ្គបញ្ជាការដ្ឋាន |
| ២-វរសេនីយ៍ទោ | ឃួ | សារ៉ែត | អត្តលេខ ០០១២៤៥ | មេបញ្ជាការរង កងកិត្តិយសត្រៃទ័ព |
| ៣-វរសេនីយ៍ទោ | ថ្លាំ | ធឿន | អត្តលេខ ០០៤៥៥៧ | នាយរងសាលាហ្វឹកហ្វឺន បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស |
| ៤-វរសេនីយ៍ទោ | សួខ | សារិន | អត្តលេខ ០០២៥៣៥ | មេបញ្ជាការរង កងរាជអាវុធហត្ថខេត្តសៀមរាប |
| ៥-វរសេនីយ៍ទោ | ម៉ិច | ខ្សៀន | អត្តលេខ ០០០៨៨៨ | មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងរតនៈគិរី |
| ៦-វរសេនីយ៍ទោ | ទៀប | ខុន្ធី | អត្តលេខ ០០៣១៥៥ | នាយការិយាល័យទី២ យោធភូមិភាគពិសេស |

៧-វរសេនីយ៍ទោ គត ឈន អត្តលេខ ០០២៨២៨ មេបញ្ជាការរង និងជានាយសេនាធិការ តំបន់ប្រតិបត្តិការសឹករងកំពត

៨-វរសេនីយ៍ទោ នៅ សឿន អត្តលេខ ០០០៩៤៦ នាយទាហានយោធភូមិភាគទី៣ តំបន់ប្រតិបត្តិការសឹករងកំពត

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. ១៤០ MOC / M 2003

# ប្រកាស

## ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ នាយកដ្ឋានស្ថិតិ និងពត៌មាន

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ១២៦ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០០២ ស្តីពីការបង្កើតនាយកដ្ឋានស្ថិតិ និងពតិមានចំណុះ អគ្គនាយកដ្ឋានបច្ចេកទេស នៃក្រសួងពាណិជ្ជកម្ម
- តាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សំរេច

**ប្រការ១ :**

នាយកដ្ឋានស្ថិតិ និងពតិមានស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់អគ្គនាយកដ្ឋានបច្ចេកទេស មានតួនាទី និងភារកិច្ចដូចតទៅ ៖-

- ស្រាវជ្រាវ និងធ្វើស្ថិតិពាណិជ្ជកម្ម
- ធ្វើសហប្រតិបត្តិការលើវិស័យស្ថិតិ ពាណិជ្ជកម្ម ជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក
- សិក្សា និងសហការជាមួយអង្គភាពពាក់ព័ន្ធ រៀបចំ អង្កេត ប្រមូល ចងក្រង និងវិភាគពិតមានស្ថិតិពាណិជ្ជកម្ម
- ចងក្រង និង ណែនាំអនុវត្តដោយឯកភាព តាមចំណាត់ថ្នាក់ពតិមានស្ថិតិពាណិជ្ជកម្ម និងបណ្តាតារាងគំរូ
- ផ្សព្វផ្សាយទិន្នន័យស្ថិតិពាណិជ្ជកម្ម ស្តីពីស្ថានភាពនៃការវិវត្តន៍ក្នុងផ្នែកពាណិជ្ជកម្មក្នុង និងក្រៅប្រទេស
- ស្រាវជ្រាវ វិភាគ ផ្សព្វផ្សាយការប្រែប្រួលថ្លៃទំនិញចរាចរក្នុងប្រទេស និងត្រួតពិនិត្យតាមដាននិន្នាការសន្ទស្សន៍ថ្លៃរបស់បណ្តាប្រទេសនានា
- សិក្សា ស្រាវជ្រាវ ប្រមូល និងវិភាគពតិមានតាមលំដាប់ដើម្បីបង្កើតតារាង នៃការប្រែប្រួលថ្លៃ និងការ

STATISTIC

ប្រែប្រួលគុណភាព
- ប្រមូលយកពតិមានអំពីថ្លៃទំនិញប្រើប្រាស់និងសេវាកម្មតាមការកំណត់ និងចងក្រងការប្រែប្រួលថ្លៃទំនិញប្រើប្រាស់និង សេវាប្រចាំខែ ត្រីមាស ៩ខែ និងប្រចាំឆ្នាំ
- ធ្វើគំរោងបណ្តុះបណ្តាលសមត្ថភាពមន្ត្រីជំនាញផ្នែកស្ថិតិពាណិជ្ជកម្ម និងពតិមានពាណិជ្ជកម្មពីថ្នាក់កណ្តាលរហូតដល់មូលដ្ឋានតាមតំរូវការការងារ
- ទទួលបន្ទុកជា មជ្ឈមណ្ឌលពតិមានពាណិជ្ជកម្ម របស់ក្រសួង
- គ្រប់គ្រង និង អភិវឌ្ឍន៏ពតិមាន ប្រពន្ធ័ទិន្នន័យសេដ្ឋកិច្ចពាណិជ្ជកម្ម
- គ្រប់គ្រងនិង អភិវឌ្ឍន៏បច្ចេកទេសពតិមានវិទ្យា ។

**ប្រការ២ :**

បង្កើតការិយាល័យចំនួន ៤ ចំណុះនាយកដ្ឋានស្ថិតិ និង ពតិមាន :
- ការិយាល័យសំរបសំរួល
- ការិយាល័យសរុបស្ថិតិពតិមានពាណិជ្ជកម្ម
- ការិយាល័យបច្ចេកទេសពិតមានវិទ្យា
- ការិយាល័យផ្សព្វផ្សាយពិតមានពាណិជ្ជកម្ម

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ។ ការិយាល័យនីមួយៗធ្វើអន្តរកម្មដើម្បីផលប្រយោជន៏របស់វិស័យស្ថិតិ និងពតិមានពាណិជ្ជកម្ម ។

**ប្រការ៣ :**

ការិយាល័យសំរបសំរួល ទទួលបន្ទុក :
- គ្រប់គ្រង និងចរាចរលិខិតរដ្ឋបាលផ្សេងៗរបស់នាយកដ្ឋានដោយធានាប្រសិទ្ធិភាព និងសុវត្ថិភាពឯកសារ
- សំរបសំរួលការងាររបស់នាយកដ្ឋានជាមួយការិយាល័យចំណុះ
- គ្រប់គ្រងអចលនទ្រព្យ និងចលនទ្រព្យក្នុងនាយកដ្ឋាន
- ស្រាវជ្រាវ និងអភិវឌ្ឍន៏បច្ចេកទេសពតិមានវិទ្យា
- ធ្វើគំរោងបណ្តុះបណ្តាលសមត្ថភាពមន្ត្រីជំនាញស្ថិតិពាណិជ្ជកម្ម និង ពតិមានពាណិជ្ជកម្ម
- គ្រប់គ្រងសំណុំឯកសារមន្ត្រីក្នុងនាយកដ្ឋាន ។

**ប្រការ៤ :**

ការិយាល័យសរុបស្ថិតិពតិមានពាណិជ្ជកម្ម ទទួលបន្ទុក :
- ធ្វើរបាយការណ៏បូកសរុបការងារជូនថ្នាក់ដឹកនាំ
- រៀបចំបង្កើតគំរូតារាងលំអិតផ្សេងៗដើម្បីជាមូលដ្ឋានឱ្យនាយកដ្ឋាននិងមន្ទីរពាណិជ្ជកម្មខេត្តក្រុងរាយការណ៏
- វិភាគ ស្ថិតិពតិមានពាណិជ្ជកម្ម និងវិភាគពីការប្រែប្រួលក្នុងវិស័យពាណិជ្ជកម្ម នាំចេញ នាំចូល អាជីវកម្ម សេវាកម្ម ។
- ធ្វើសហការវិស័យស្ថិតិពាណិជ្ជកម្មជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក
- ធ្វើស្ថិតិថ្លៃទំនិញ សំខាន់ៗ ដែលចរាចរលើទីផ្សារក្នុងប្រទេស និងក្រៅប្រទេស និងធ្វើសន្ទស្សន៏ថ្លៃទំនិញទាំងនោះ ។

**ប្រការ៥ :**

ការិយាល័យបច្ចេកទេសពិតមានវិទ្យា ទទួលបន្ទុក :
- រៀបចំគេហទំព័រ (Home page) និងផ្សព្វផ្សាយលើ Website ពីទិន្នន័យស្ថិតិពាណិជ្ជកម្ម

- ផ្សព្វផ្សាយច្បាប់ទាក់ទងដល់ពាណិជ្ជកម្ម និងច្បាប់របស់អង្គការពាណិជ្ជកម្មពិភពលោកដល់ពាណិជ្ជករ និងក្រុមហ៊ុនក្នុងស្រុក
- ទទួលផ្សាយពាណិជ្ជកម្មតាម Website

**ប្រការ៦:**

ការិយាល័យផ្សព្វផ្សាយពិតមានពាណិជ្ជកម្ម ទទួលបន្ទុក :

- រៀបចំស្ថិតិប្រចាំថ្ងៃ ប្រចាំអាទិត្យ ខែ ត្រីមាស ឆមាស ៩ខែ និងឆ្នាំជូនក្រសួង
- ផ្តល់ពិតមានសំរាប់នាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេសចុះផ្សាយក្នុងព្រឹត្តិប័ត្ររបស់ក្រសួងពាណិជ្ជកម្ម
- ធ្វើសេវាផ្តល់ពិតមានទាក់ទងស្ថិតិពាណិជ្ជកម្មកម្ពុជានិងពិភពលោកដោយយកកំរៃរដ្ឋបាលមួយសមស្រប ។

**ប្រការ៧ :**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៨ :**

អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានស្ថិតិ និងពតិមាន ប្រធាននាយកដ្ឋានបុគ្គលិក និងប្រធាននាយកដ្ឋានពាក់ពន្ធ័ ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០០៣

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

កន្លែងទទួល :

-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់នាយកដ្ឋាន មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង
-ដូចប្រការ៨
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. ១៤១ MOC / M 2003

# ប្រកាស

## ស្តីពីការបង្កើតបន្ថែមការិយាល័យមួយចំណុះ
## នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ-អាហរ័ណ
## និងបង្ក្រាបការក្លែងបន្លំ

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងពាណិជ្ជកម្ម
- យោងលិខិត លេខ ១០៩៣ សជណ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការបង្កើតមជ្ឈមណ្ឌលទំនាក់ទំនង ផ្តល់ពត៌មានសំរាប់អនុវត្តកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មអន្តរជាតិ
- តាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សំរេច

**ប្រការ១:_**

បង្កើតបន្ថែម ការិយាល័យ "ផ្តល់ចំលើយការអនុវត្តវិធានការណ៍អនាម័យ និងភូតគាមអនាម័យ" ស្ថិតក្រោម នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ "កាំកុងត្រូល" ។

**ប្រការ២:_**

ការិយាល័យផ្តល់ចំលើយផ្នែកអនុវត្តវិធានការណ៍អនាម័យ និងភូតគាមអនាម័យ មានភារកិច្ចដូចខាងក្រោម ៖-

- ទទួលផ្តល់ពត៌មាន ពាក់ព័ន្ធ នឹងការអនុវត្តន៏វិធានការណ៍អនាម័យ និងភូតគាម អនាម័យ ក្នុងវិស័យពាណិជ្ជកម្មអន្តរជាតិ
- សំរបសំរួល សហការ ប្រមូលផ្តុំពត៌មាន ជាមួយកូដិចជាតិ និងក្រសួងពាក់ព័ន្ធក្នុងការផ្តល់ចម្លើយជូនលេខាធិការដ្ឋាន អង្គការពាណិជ្ជកម្មពិភពលោក
- តាមដាន ប្រមូលផ្តុំពត៌មានថ្មីៗ អំពីបាតុភាពផ្នែកវិធានការណ៍ អនាម័យ និងភូតគាមអនាម័យ ជាក់លាក់ដែលមានប្រយោជន៏ដល់កម្ពុជា នៅបណ្តាប្រទេស
- ផ្តល់គំនិតជូនលេខាធិការដ្ឋានគណៈកម្មាធិការកូដិចជាតិ អំពីផលប៉ះពាល់ដល់កម្ពុជា នៃបណ្តាការងារកសាងស្តង់ដារម្ហូបអាហារ បញ្ហាត្រួតពិនិត្យម្ហូបអាហារ និងបញ្ហាភូតគាមអនាម័យ

- ធ្វើការផ្សព្វផ្សាយ អនុវត្តក្នុងប្រទេសនូវពត៌មានអំពីបណ្តាវិធានការទាក់ទងនឹងអនាម័យ និង ភូតគាមអនាម័យ
- ជំនួយការងារផ្នែកលេខាធិការ និងរដ្ឋបាលសំរាប់លេខាធិការដ្ឋានគណៈកម្មាធិការ កូដិចជាតិ
- ទទួលរាល់ការងារដែលលេខាធិការដ្ឋានគណៈកម្មាធិការកូដិចជាតិ និងនាយកដ្ឋានកាំកុងត្រូលប្រគល់អោយ ។

**ប្រការ៣:**

ការិយាល័យផ្តល់ចំលើយការអនុវត្តវិធានការណ៍អនាម័យ និងភូតគាមអនាម័យ ត្រូវដឹកនាំដោយ ប្រធានការិយាល័យមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ។

**ប្រការ៤:**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៥:**

អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនិហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ និង ប្រធានលេខាធិការដ្ឋានគណៈកម្មាធិការកូដិចជាតិ ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០០៣

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចាម_ប្រសិទ្ធ**

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- គ្រប់នាយកដ្ឋាន មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. ១៥២ MOC / M 2003

# ប្រ កា ស

## ស្តីពីការបង្កើតបន្ថែមការិយាល័យពីរចំណុះ នាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងពាណិជ្ជកម្ម
- យោងលិខិត លេខ ១០៩៣ សជណ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការបង្កើតមជ្ឈមណ្ឌលទំនាក់ទំនង ផ្តល់ពត៌មានសំរាប់អនុវត្តកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មអន្តរជាតិ
- តាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សំ រេ ច

**ប្រការ១ :**

បង្កើតការិយាល័យចំនួន ០២ ស្ថិតក្រោមនាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ :

១- ការិយាល័យផ្តល់ ទទួលពត៌មានសេវាកម្ម

២- ការិយាល័យផ្ទៀងផ្ទាត់ភាពស្របគ្នានៃច្បាប់ និងបទប្បញ្ញត្តិ នៃអង្គការពាណិជ្ជកម្មពិភពលោក

**ប្រការ២ :**

ការិយាល័យផ្តល់ ទទួលពត៌មានសេវាកម្ម មានភារកិច្ច :

- ប្រមូលផ្តុំពត៌មានសេវាកម្ម ពីអន្តរក្រសួងពាក់ព័ន្ធ ដើម្បីបញ្ជូនទៅ លេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោកជាប្រចាំ
- សហការជាមួយការិយាល័យផ្ទៀងផ្ទាត់ភាពស្របគ្នានៃច្បាប់ និងបទប្បញ្ញត្តិ នៃអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីផ្តល់យោបល់លើអត្ថបទច្បាប់ និងលិខិតបទដ្ឋានដែលទាក់ទងដល់សេវាកម្ម
- សំរបសំរួល និងផ្សព្វផ្សាយការអនុវត្តនីរាល់ការងារសេវាកម្មដល់វិស័យឯកជន និងស្ថាប័នពាក់ព័ន្ធ
- សហការណ៏ជាមួយការិយាល័យអង្គការពាណិជ្ជកម្មពិភពលោកដើម្បីប្រមូលផ្តុំ និង ចងក្រងឯកសារសំរាប់ការចរចាដោះស្រាយរាល់បណ្តឹងតវ៉ាលើការអនុវត្តន៏ច្បាប់ និងលិខិតបទដ្ឋានរបស់កម្ពុជា ដែលទាក់ទងនឹងការងារសេវាកម្ម ។

**ប្រការ៣ :**

ការិយាល័យផ្ទៀងផ្ទាត់ភាពស្របគ្នា នៃច្បាប់ និងបទបញ្ញត្តិនៃអង្គការពាណិជ្ជកម្មពិភពលោក មានភារកិច្ច :

- ត្រួតពិនិត្យលើភាពស្របគ្នា និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋានដែលទាក់ទងដល់កិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក សន្ធិសញ្ញា និងកិច្ចព្រមព្រៀងនានា ដែលពាក់ព័ន្ធនឹងការងារពាណិជ្ជកម្ម
- ប្រមូលផ្តុំនិងផ្តល់ពត៌មានអំពីច្បាប់និងលិខិតបទដ្ឋានរបស់កម្ពុជាជូនអង្គការពាណិជ្ជកម្មពិភពលោកជាប្រចាំ
- ទុកដាក់ និងថែរក្សានូវឯកសារដែលទទួលពីអង្គការពាណិជ្ជកម្មពិភពលោក និងពីក្រសួងនានា
- សំរបសំរួលជាមួយការិយាល័យអង្គការពាណិជ្ជកម្មពិភពលោកក្នុងការផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋានរបស់កម្ពុជា
- សំរបសំរួល និងផ្សព្វផ្សាយការអនុវត្តន៍កិច្ចព្រមព្រៀង សន្ធិសញ្ញាពាណិជ្ជកម្ម ដល់ស្ថាប័នរដ្ឋ និងវិស័យឯកជន ។

**ប្រការ៤ :**

ការិយាល័យផ្តល់ ទទួលពត៌មានសេវាកម្ម និង ការិយាល័យផ្ទៀងផ្ទាត់ភាពស្របគ្នា នៃច្បាប់និងបទបញ្ញត្តិ នៃអង្គការពាណិជ្ជកម្មពិភពលោក ដឹកនាំតាមការិយាល័យនីមួយៗដោយប្រធានការិយាល័យមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ។

**ប្រការ៥ :**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៦ :**

អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានអាស៊ាននិងអង្គការអន្តរជាតិ ប្រធាននាយកដ្ឋានបុគ្គលិក ត្រូវអនុវត្តប្រកាសនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០០៣

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

កន្លែងទទួល :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
-គ្រប់នាយកដ្ឋាន មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង
-ដូចប្រការ៦
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពត៌មាន**

លេខ.....០៥៨.../០៣ ព.ម

រាជធានីភ្នំពេញ,ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៣

# ប្រកាស
# ស្តីពី
# រដ្ឋមន្ត្រីក្រសួងពត៌មាន

******

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ។
- បានឃើញព្រះរាជក្រឹត្យ ន . ស . រ . ក . ត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខ ន.ស.រ.ក.ម ០១៩៦ /១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពតិមាន ។
- បានឃើញព្រះរាជក្រមលេខ នស /រកម ០៨៩៥-០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសារពតិមាន ។
- បានឃើញអនុក្រឹត្យលេខ ៧០ អ.ន.ក្រ.បក ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងពតិមាន ។
- បានឃើញលិខិតរបស់លោក **ឈុំ ឧុត្ឋិ** ចុះថ្ងៃទី២៥ ខែ០៤ ឆ្នាំ២០០៣ ស្តីពីសំណើសុំច្បាប់បោះពុម្ពផ្សាយកាសែត"**តតិយលោក**" ។

## សំរេច

**ប្រការ១** : អនុញ្ញាតឱ្យកាសែត "**តតិយលោក**"បោះពុម្ពចែកផ្សាយដោយមានលោក **ឈុំ ឧុត្ឋិ** ជាចាងហ្វាងការផ្សាយ។ ទីស្នាក់ការផ្ទះលេខ ១៣៤ $SEO_2$ ផ្លូវលេខ១១៨ សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

**ប្រការ២** : រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីរបបសារពតិមាន ក្រមសីលធម៌អ្នកសារពតិមាន ។

**ប្រការ៣** : ក្នុងករណីប្រព្រឹត្តល្មើសនឹងប្រការ ២ ខាងលើ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ៤** : អគ្គនាយករដ្ឋបាល និងសោតទស្សន៍ ប្រធាននាយកដ្ឋានមណ្ឌលពតិមាននៃក្រសួងពតិមាន និងចាងហ្វាងការផ្សាយកាសែត **តតិយលោក** ត្រូវអនុវត្តនូវប្រកាសនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ៥** : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល២ឆ្នាំ ។ ក្នុងករណីមិនសុំបន្តអាយុកាលនៃអាជ្ញាប័ណ្ណលើសរយៈពេល៣ខែ ក្រសួងពតិមានចាត់ទុកថា សាមីចាងហ្វាងបានបោះបង់អាជីវកម្មរបស់ខ្លួនជាស្ថាពរ ។/.

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**

__ចម្លងជូន__
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យមេធាវីរាជរដ្ឋាភិបាល
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- អភិបាលរាជធានីភ្នំពេញ
- តុលាការរាជធានីភ្នំពេញ
- ស្នងការនគរបាលរាជធានីភ្នំពេញ
- គ្រប់សមាគមអ្នកសារពតិមានកម្ពុជា
  "ដើម្បីជ្រាបជាពតិមាន"
- សាមីខ្លួន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន

លេខ ១៦៣/០៣ ព.ម

រាជធានីភ្នំពេញ,ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៣

# ប្រកាស

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងព័ត៌មាន

******

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ។
- បានឃើញព្រះរាជក្រឹត្យ ន . ស . រ . ក . ត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខ ន.ស.រ.ក.ម ០១៩៦ /១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពត៌មាន ។
- បានឃើញព្រះរាជក្រមលេខ នស /រកម ០៨៩៥-០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសារពត៌មាន ។
- បានឃើញអនុក្រឹត្យលេខ ៧០ អ.ន.ក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងពត៌មាន ។
- បានឃើញលិខិតរបស់លោក**ឈិន នាយ** ចុះថ្ងៃទី១៤ ខែ០៥ឆ្នាំ២០០៣ ស្តីពីសំណើសុំច្បាប់បោះពុម្ពផ្សាយកាសែត **កោះសុវណ្ណភូមិ** ។

## សំរេច

**ប្រការ១** : អនុញ្ញាតឱ្យកាសែត "**កោះសុវណ្ណភូមិ**" បោះពុម្ពចែកផ្សាយដោយមានលោក **ឈិន នាយ** ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការ ផ្ទះលេខ២២៥ ក្រុម ទី៣ ក្រពើហារ ព្រែកឫស្សី តាខ្មៅ ខេត្តកណ្តាល ។

**ប្រការ២** : រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីរបបសារពត៌មាន ក្រមសីលធម៌អ្នកសារពត៌មាន ។

**ប្រការ៣** : ក្នុងករណីប្រព្រឹត្តល្មើសនឹងប្រការ ២ ខាងលើ សាម៉ីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ៤** : អគ្គនាយករដ្ឋបាល និងសោតទស្សន៍ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាននៃក្រសួងពត៌មាននិងចាងហ្វាងការផ្សាយកាសែត**កោះសុវណ្ណភូមិ** ត្រូវអនុវត្តនូវប្រកាសនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ៥** : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល២ឆ្នាំ ។ ក្នុងករណីមិនសុំបន្តអាយុកាលនៃអាជ្ញាប័ណ្ណលើសរយៈពេល៣ខែ ក្រសួងពត៌មានចាត់ទុកថា សាម៉ីចាងហ្វាងបានបោះបង់អាជីវកម្មរបស់ខ្លួនជាស្ថាពរ ។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី

ចម្លងជូន

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យមេដឹកនាំរាជរដ្ឋាភិបាល
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- អភិបាលរាជធានីភ្នំពេញ
- តុលាការរាជធានីភ្នំពេញ
- ស្នងការនគរបាលរាជធានីភ្នំពេញ
- គ្រប់សមាគមអ្នកសារពត៌មានកម្ពុជា
  "ដើម្បីជ្រាបជាពត៌មាន"
- សាម៉ីខ្លួន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងព័ត៌មាន**

លេខ...១៧៤/០៣...ព.ម

រាជធានីភ្នំពេញ,ថ្ងៃទី.៣០.ខែ.ឧសភា.ឆ្នាំ.២០០៣

# ប្រកាស

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព័ត៌មាន

******

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ។
- បានឃើញព្រះរាជក្រឹត្យ ន.ស.រ.ក.ត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខ ន.ស.រ.ក.ម ០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងព័ត៌មាន ។
- បានឃើញព្រះរាជក្រមលេខនស/រកម០៨៩៥-០៧ចុះថ្ងៃទី០១ខែកញ្ញាឆ្នាំ១៩៩៥ ប្រកាសឱ្យប្រើច្បាប់ស្ដីពីរបបសារព័ត៌មាន ។
- បានឃើញអនុក្រឹត្យលេខ ៧០ អ.ន.ក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងព័ត៌មាន ។
- បានឃើញប្រកាសរបស់ក្រសួងព័ត៌មានលេខ ១៤៤/០២ ព.មប្រក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០២ ស្ដីពីការអនុញ្ញាតអោយព្រឹត្តិប័ត្រប្រចាំសប្ដាហ៍ "**គញ្ចក់សង្គម**" និង **The Mirror** ដំណើរការបោះពុម្ពចែកផ្សាយដោយមានលោក **Nobert Klein** ជាចាងហ្វាងការផ្សាយ ។
- បានឃើញលិខិតរបស់លោក **Nobert Klein** ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៣ស្ដីពីសំណើសុំបន្តអាជ្ញាបណ្ណរបស់ព្រឹត្តិប័ត្រ ប្រចាំសប្ដាហ៍ "**គញ្ចក់សង្គម**" និង "**The Mirror**" ។

## សម្រេច

**ប្រការ១** : អនុញ្ញាតឱ្យព្រឹត្តិប័ត្រប្រចាំសប្ដាហ៍ "**គញ្ចក់សង្គម**" និង "**The Mirror**" បន្តអាជ្ញាបណ្ណបោះពុម្ពចែកផ្សាយដោយមានលោក **Nobert Klein** ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការផ្ទះលេខ២៤៥ ផ្លូវលេខ៥១ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

**ប្រការ២** : ប្រកាសរបស់ក្រសួងព័ត៌មានលេខ ១៤៤/០២ ព.មប្រក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០២ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៣** : រាល់ដំណើរការបោះពុម្ពចែកផ្សាយ ត្រូវគោរពតាមច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្ដីពីរបបសារព័ត៌មាន ក្រមសីលធម៌អ្នកសារព័ត៌មាន ។

**ប្រការ៤** : ក្នុងករណីប្រព្រឹត្តល្មើសនឹងប្រការ៣ ខាងលើសាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ៥** : អគ្គនាយករដ្ឋបាល និងសោតទស្សន៍ ប្រធាននាយកដ្ឋានមណ្ឌលព័ត៌មាននៃក្រសួងព័ត៌មាន និងចាងហ្វាងការផ្សាយព្រឹត្តិប័ត្រ ប្រចាំសប្ដាហ៍ "**គញ្ចក់សង្គម**"និង "**The Mirror**" ត្រូវអនុវត្តនូវប្រកាសនេះ ។

**ប្រការ៦** : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល១ឆ្នាំ ។ ក្នុងករណីមិនសុំបន្តអាយុកាលនៃអាជ្ញាប័ណ្ណលើសរយៈពេល៣ខែ ក្រសួង ព័ត៌មានចាត់ទុកថា សាមីចាងហ្វាងបានបោះបង់អាជីវកម្មរបស់ខ្លួនជាស្ថាពរ ។

**ចម្លងជូន**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យមេធាវីរាជរដ្ឋាភិបាល
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- អភិបាលរាជធានីភ្នំពេញ
- តុលាការរាជធានីភ្នំពេញ
- ស្នងការនគរបាលរាជធានីភ្នំពេញ
- គ្រប់សមាគមអ្នកសារព័ត៌មានកម្ពុជា "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**

លី. ឡាយស្រេង

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងពត៌មាន**

លេខ ២២៥/០៣ ព.ម ប្រ.ក

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែឧសភា ឆ្នាំ ២០០៣

# ប្រកាស

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងពត៌មាន

******

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ។
- បានឃើញព្រះរាជក្រឹត្យ ន . ស . រ . ក . ត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខ ន.ស.រ.ក.ម ០១៩៦ /១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពតិមាន ។
- បានឃើញព្រះរាជក្រមលេខ នស /រកម ០៨៩៥-០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសារពតិមាន ។
- បានឃើញអនុក្រឹត្យលេខ ៧០.អ.ន.ក្រ.បក ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងពតិមាន ។
- បានឃើញលិខិតរបស់លោកស្រី**អេង សុខខឹង** ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៣ ស្តីពីសំណើសុំច្បាប់បោះពុម្ពផ្សាយកាសែត **ព្រះខន់** ។

## សម្រេច

**ប្រការ១** : អនុញ្ញាតឱ្យកាសែត**ព្រះខន់** បោះពុម្ពចែកផ្សាយដោយមានលោកស្រី**អេង សុខខឹង** ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការផ្ទះលេខ៤E₀ ផ្លូវលេខ៣៩០ ក្រុមទី១០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**ប្រការ២** : រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីរបបសារពតិមាន ក្រមសីលធម៌អ្នកសារពតិមាន ។

**ប្រការ៣** : ក្នុងករណីប្រព្រឹត្តល្មើសនឹងប្រការ ២ ខាងលើ សាម៉ីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ៤** : អគ្គនាយករដ្ឋបាល និង សោតទស្សន៍ ប្រធាននាយកដ្ឋានមណ្ឌលពតិមាននៃក្រសួងពតិមាន និង ចាងហ្វាងការផ្សាយកាសែត **ព្រះខន់** ត្រូវអនុវត្តនូវប្រកាសនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ៥** : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល២ឆ្នាំ ។ ក្នុងករណីមិនសុំបន្តអាយុកាលនៃអាជ្ញាប័ណ្ណលើសរយៈពេល៣ខែ ក្រសួងពតិមានចាត់ទុកថា សាម៉ីចាងហ្វាងបានបោះបង់អាជីវកម្មរបស់ខ្លួនជាស្ថាពរ ។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**

ខៀវ កាញារីទ្ធ

ចម្លងជូន

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យមេដឹកនាំរាជរដ្ឋាភិបាល
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- អភិបាលរាជធានីភ្នំពេញ
- តុលាការរាជធានីភ្នំពេញ
- ស្នងការនគរបាលរាជធានីភ្នំពេញ
- គ្រប់សមាគមអ្នកសារពតិមានកម្ពុជា
  "ដើម្បីជ្រាបជាពតិមាន"
- សាម៉ីខ្លួន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពត៌មាន**

លេខ ១៦៦/០៣ ព.ម-ប្រ.ក

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៣

## ប្រកាស
## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងពត៌មាន

******

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ។
- បានឃើញព្រះរាជក្រឹត្យ ន . ស . រ . ក . ត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខ ន.ស.រ.ក.ម ០១៩៦ /១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពតិមាន ។
- បានឃើញព្រះរាជក្រមលេខ នស /រកម ០៨៩៥-០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសារពតិមាន ។
- បានឃើញអនុក្រឹត្យលេខ ៧០ អ.ន.ក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងពតិមាន ។
- បានឃើញលិខិតរបស់លោកស្រី **សុខ ខុម** ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៣ ស្តីពីសំណើសុំច្បាប់បោះពុម្ពផ្សាយកាសែត "**ចក្រភព**" ។

## សំរេច

**ប្រការ១** : អនុញ្ញាតឱ្យកាសែត "**ចក្រភព**" បោះពុម្ពចែកផ្សាយដោយមានលោកស្រី**សុខ ខុម** ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការផ្ទះលេខ៤$E_0$ ផ្លូវលេខ៣៩០ ក្រុម១០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**ប្រការ២** : រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីរបបសារពតិមាន ក្រមសីលធម៌អ្នកសារពតិមាន ។

**ប្រការ៣** : ក្នុងករណីប្រព្រឹត្តល្មើសនឹងប្រការ ២ ខាងលើ សាម៉ីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ៤** : អគ្គនាយករដ្ឋបាល និង សោតទស្សន៍ ប្រធាននាយកដ្ឋានមណ្ឌលពតិមាននៃក្រសួងពតិមាន និង ចាងហ្វាងការផ្សាយកាសែត **ចក្រភព** ត្រូវអនុវត្តនូវប្រកាសនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ៥** : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល២ឆ្នាំ ។ ក្នុងករណីមិនសុំបន្តអាយុកាលនៃអាជ្ញាប័ណ្ណលើសរយៈពេល៣ខែ ក្រសួងពតិមានចាត់ទុកថា សាម៉ីចាងហ្វាងបានបោះបង់អាជីវកម្មរបស់ខ្លួនជាស្ថាពរ ។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**

ចម្លងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យមេធាវីរាជរដ្ឋាភិបាល
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- អភិបាលរាជធានីភ្នំពេញ
- តុលាការរាជធានីភ្នំពេញ
- ស្នងការនគរបាលរាជធានីភ្នំពេញ
- គ្រប់សមាគមអ្នកសារពតិមានកម្ពុជា "ដើម្បីជ្រាបជាពតិមាន"
- សាម៉ីខ្លួន